មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដ
ស៍ សើស្បែក និងកាមរោគ

# សិក្ខាសាលាថ្នាក់តំបន់ ស្តីពី «ការពិនិត្យមើលលទ្ធផល និងការពង្រឹងគុណភាពជាបន្ត ក្នុងការស្វែងរកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥.៩៥.៩៥»



មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំវគ្គសិក្ខាសាលាថ្នាក់តំបន់ ស្តីពី « ការពិនិត្យមើលលទ្ធផល និងការពង្រឹងគុណភាពជាបន្ត ក្នុងការស្វែងរកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥.៩៥.៩៥ » ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៩ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ នៅមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តតាកែវ ដោយមានការគាំទ្រថវិកា និងបច្ចេកទេស ដោយគម្រោង US-CDC Cambodia ។ គោលបំណង នៃសិក្ខាសាលានេះ គឺដើម្បីជាជាន់ លទ្ធផល និងសមមាត្រខ្ពស់ នៃល្បាក់ទាំងមូលតាំងពីការរកឃើញអ្នកផ្ទុកមេរោគអេដស៍ រហូតដល់ចុះឈ្មោះ





ទទួលសេវាថែទាំ និងព្យាបាលប្រកបដោយគុណភាព។ សិក្ខាសាលានេះក្រោមអធិបតី លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ អេដស៍ សើស្បែក និងកាមរោគ លោកឱសថការី ផាន់ វ៉ាន់ ប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាល ខេត្តតាកែវ និង លោកវេជ្ជ.

ចាន់ សុដារា អ្នកជំនាញសុខភាពសាធារៈ តំណាងអោយមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺរបស់សហរដ្ឋអាមេរិករួម ដែលបានផ្តល់មតិសំណេះសំណាល ក្នុងនោះលោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា បានចូលរួមជាមតិយោបល់ព្រមទាំងប្រកាសបើកអង្គសិក្ខាសាលា។

សិក្ខាសាលានេះមានការចូលរួមពីផ្នែកជំនាញរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដូចជា ផ្នែក AIDS Care ផ្នែក BCC ផ្នែក STI ផ្នែក Laboratory ផ្នែក DMU ផ្នែក VCCT ផ្នែក Technical Bureau គ្លីនិក NCHADS និងមានការចូលរួមពី ប្រធានកម្មវិធីអេដស៍ខេត្ត ប្រធានក្រុម ART មកពីតាមបណ្តាខេត្តជាជា និងអង្គការដៃគូ ដូចជា MHC និង PC សរុបចំនួន ៥២ នាក់។ សិក្ខាសាលា



មានការធ្វើបទបង្ហាញពីលទ្ធផលដែលសម្រេចបាននៅតាមសូចនាករ សំខាន់ៗ ទាក់ទង នឹង៩៥ទី១៖ ចំនួនអ្នកមានតេស្តប្រតិកម្មរកឃើញថ្មី ភាគរយអ្នកបញ្ជាក់ថាវិជ្ជមាន HIV បានចុះឈ្មោះនៅ សេវា ART ចំនួន HIVST បានធ្វើតេស្តបញ្ជាក់ មានលទ្ធផលតេស្តបញ្ជាក់វិជ្ជមាន HIV និងលទ្ធផលសម្រេចបាននៃសូចនាករសំខាន់ៗទាក់ទងនឹង ៩៥ទី២ និង៩៥ទី៣៖ ភាគរយអ្នកជំងឺ ART ដែលបានស្លាប់ អ្នកជំងឺខកណាត់ និងបាត់មុខដែលបានដាក់អោយទទួល សេវាវិញ ការពិនិត្យតាមការណាត់ មុនថ្ងៃណាត់ យឺតជៅថ្នាំបម្រុង យឺតអស់ថ្នាំបម្រុង និងកំណត់បញ្ហាអាទិភាព មូលហេតុដែលទាក់ទងនឹងលទ្ធផលនៃសូចនាករទាប និងរៀបចំផែនការសកម្មភាពដើម្បីកែលម្អរនៅ។

